ក្រសួងផែនការ
អគ្គនាយកដ្ឋានផែនការ
នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

# មេរៀនទី៩៖ ការតាមដានត្រួតពិនិត្យ

ដល់គ្រូបង្គោលថ្នាក់រាជធានី ខេត្ត/ថ្នាក់ក្រុង ស្រុក ខណ្ឌ

(តំបន់ទី____) ខេត្ត ____,ថ្ងៃទី ____ ខែ ____ ឆ្នាំ២០២២

Australian Aid

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ៖
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

UNDP

| | |
|---|---|
| គោលបំណង | **នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹងអាច៖**<br>• បរិយាយនិងអនុវត្តដំណើរការតាមដានត្រួតពិនិត្យ<br>• អនុវត្តការបណ្តុះបណ្តាលបន្តនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| សរបេរយ:ពេល | ៣០នាទី |
| សម្ភារ:ចាំបាច់ | LCD ក្រដាសផ្ទាំងធំ ហ្វឹត ស្កុត ខ្លឹមសារមេរៀនសង្ខេប |
| វិធីសាស្រ្ត | បំផុសគំនិត និងពន្យល់ខ្លឹមសារមេរៀន |

# មាតិកា

១. ការងារតាមដាន និងត្រួតពិនិត្យការគ្រប់គ្រងនិងការអនុវត្តនីតិវិធី ៤

១.១. សកម្មភាពការតាមដានត្រួតពិនិត្យរបស់ថ្នាក់ជាតិ

៥

១.២. លេខាធិការដ្ឋាន

៦

១.៣. មន្ត្រីសម្របសម្រួលបច្ចេកទេស

៧

២. ការតាមដានគុណភាពទិន្នន័យ ៨

២.១. ក្រុមការងារថ្នាក់ជាតិ

៩

- ១. ការងារតាមដាន និងត្រួតពិនិត្យការគ្រប់គ្រងនិងការអនុវត្តនីតិវិធី
    - ១.១. សកម្មភាពការតាមដានត្រួតពិនិត្យរបស់ថ្នាក់ជាតិ
    - ១.២. លេខាធិការដ្ឋាន
    - ១.៣. មន្ត្រីសម្របសម្រួលបច្ចេកទេស

# ១.១ សកម្មភាពការតាមដានត្រួតពិនិត្យរបស់ថ្នាក់ជាតិ

- រៀបចំផែនការសកម្មភាពចុះតាមដាននិងត្រួតពិនិត្យ តាមចំនួនសំណាកដែលនឹងជ្រើសរើសដោយចៃដន្យ
- ចុះតាមដាន និងត្រួតពិនិត្យ តាមមតិជំទាស់និងសំណូមពររបស់ប្រជាពលរដ្ឋ និងរបាយការណ៍ពីភាពមិនប្រក្រតីដែលបានរកឃើញដោយអ្នកពាក់ព័ន្ធដទៃទៀត។
- ចុះជួបជាមួយមន្ត្រីលេខាធិការដ្ឋាន ដើម្បីប្រជុំពិភាក្សាពីវឌ្ឍនភាពការងារនិងព័ត៌មានដែលបានទទួលពី៖
  - ប្រព័ន្ធមូលដ្ឋានទិន្នន័យថ្នាក់ជាតិ (ចំនួនពាក្យស្នើសុំសម្ភាសន៍ ចំនួនគ្រួសារដែលបានសម្ភាសន៍រួច ចំនួនគ្រួសារដែលបានអនុម័តថាជាគ្រួសារក្រីក្រ ចំនួនគ្រួសារដែលបានដកចេញពីបញ្ជីគ្រួសារក្រីក្រ និងចំនួនគ្រួសារដែលកែសម្រួលព័ត៌មានរបស់គ្រួសារ)
  - មុខងារតាមដាន និងត្រួតពិនិត្យរបស់ IDPoor App
  - មតិជំទាស់និងសំណូមពរពី Public IDPoor App
- ឆ្លើយតបរាល់ការសុំជំនួយបច្ចេកទេស និងបញ្ហាផ្សេងៗ ក្នុងករណីដែលមន្ត្រីលេខាធិការដ្ឋានមិនអាចដោះស្រាយបាន
- ចុះផ្ទាល់ដល់មូលដ្ឋានបន្ថែមលើសំណាកចៃដន្យ ក្នុងករណីរកឃើញមតិជំទាស់និងសំណូមពរតាមរយៈកម្មវិធី Public IDPoor App និងភាពមិនប្រក្រតីដែលរកឃើញនៅក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យថ្នាក់ជាតិ
- ត្រូវរៀបចំរបាយការណ៍តាមដានត្រួតពិនិត្យប្រចាំត្រីមាសសម្រាប់រាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងផែនការ។

# ១.២. លេខាធិការដ្ឋាន

- ត្រូវរៀបចំផែនការសកម្មភាពចុះតាមដាន និងត្រួតពិនិត្យតាមសំណាកដែលជ្រើសរើសដោយចៃដន្យពីថ្នាក់ជាតិ និងយោងទៅតាមមតិជំទាស់និងសំណូមពររបស់ប្រជាពលរដ្ឋ និងរបាយការណ៍ពីភាពមិនប្រក្រតីដែលបានរកឃើញដោយអ្នកពាក់ព័ន្ធដទៃទៀត
- ចុះជួបជាមួយក្រុមការងារឃុំ សង្កាត់ ដើម្បីប្រជុំពិភាក្សាពីវឌ្ឍនភាពការងារ និងព័ត៌មានដែលបានទទួលពីៈ
  - ប្រព័ន្ធមូលដ្ឋានទិន្នន័យថ្នាក់ជាតិ (ចំនួនពាក្យស្នើសុំសម្ភាសន៍ ចំនួនគ្រួសារដែលបានសម្ភាសន៍ ចំនួនគ្រួសារដែលបានអនុម័តជាគ្រួសារក្រីក្រ ចំនួនគ្រួសារដែលបានដកចេញពីបញ្ជីគ្រួសារក្រីក្រ និងចំនួនគ្រួសារដែលកែសម្រួលព័ត៌មានរបស់គ្រួសារ)
  - មតិជំទាស់និងសំណូមពរតាមរយៈកម្មវិធី Public IDPoor App
- ត្រូវប្រើប្រាស់មុខងារតាមដាននិងត្រួតពិនិត្យរបស់ IDPoor App សម្រាប់ប្រមូលគ្រប់ព័ត៌មាន និងធ្វើរបាយការណ៍
- ឆ្លើយតបរាល់ការសុំជំនួយបច្ចេកទេស និងបញ្ហាផ្សេងៗ ក្នុងករណីដែលក្រុមការងារឃុំ សង្កាត់មិនអាចដោះស្រាយបាន
- ត្រូវចុះទៅផ្ទាល់ដល់មូលដ្ឋានបន្ថែមលើសំណាកចៃដន្យ ក្នុងករណីទទួលបានមតិជំទាស់និងសំណូមពរ
- ត្រូវរៀបចំរបាយការណ៍តាមដានត្រួតពិនិត្យប្រចាំត្រីមាស សម្រាប់រាយការណ៍ជូនគណៈកម្មាធិការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះរាជធានី ខេត្ត និងក្រុមការងារថ្នាក់ជាតិ។

# ១.៣. មន្ត្រីសម្របសម្រួលបច្ចេកទេស

- ត្រូវសហការណ៍ជាមួយមន្ត្រីលេខាធិការដ្ឋានចុះតាមដានត្រួតពិនិត្យការអនុវត្តការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅតាមឃុំ សង្កាត់ដែលខ្លួនទទួលខុសត្រូវជាប្រចាំ
- ត្រូវចុះតាមដានត្រួតពិនិត្យទៅលើការដាក់ពាក្យស្នើសុំការសម្គាសន៍គ្រួសារ ការអនុម័តគ្រួសារក្រីក្រ និងការដកគ្រួសារដែលមានជីវភាពប្រសើរចេញពីបញ្ជីគ្រួសារក្រីក្រ។ល។
- ត្រូវរាយការណ៍ពីមតិជំទាស់និងសំណូមពរផ្សេងៗដែលមិនអាចដោះស្រាយបានទៅកាន់ប្រធានលេខាធិការដ្ឋានដើម្បីដោះស្រាយ
- ត្រូវរៀបចំរបាយការណ៍ប្រចាំត្រីមាសស្ដីពីលទ្ធផលតាមដានត្រួតពិនិត្យការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងក្រុង ស្រុក ខណ្ឌ ជូនប្រធានលេខាធិការដ្ឋាន។


idpoor.gov.kh fb.com/IDPoor Cambodia https://t.me/idpoorcambodia 023 726 814 youtube.com/IDPoor Cambodia

# ២. ការតាមដានគុណភាពទិន្នន័យ

**គោលបំណង៖** ដើម្បីវាយតម្លៃអំពីគុណភាពនិងសុក្រឹតភាពទិន្នន័យ។

**វិធីសាស្ត្រ៖**

- ថ្នាក់ជាតិជ្រើសរើសសំណាកចៃដន្យពីប្រព័ន្ធមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ
  - គ្រួសារកាន់បណ្ណសមធម៌មានសុពលភាព
  - គ្រួសារគ្មានបណ្ណសមធម៌
- ចុះធ្វើការសម្ភាសន៍ពិនិត្យវាយតំលៃពីគុណភាពទិន្នន័យដោយដោយសហការជាមួយថ្នាក់ក្រោមជាតិ។

២.១. ក្រុមការងារថ្នាក់ជាតិ

២.២. មន្ត្រីលេខាធិការដ្ឋាន

២.៣. មន្ត្រីសម្របសម្រួលបច្ចេកទេស

## ២.១. ក្រុមការងារថ្នាក់ជាតិ

- ជ្រើសរើសសំណាកគំរូចៃដន្យពីប្រព័ន្ធមូលដ្ឋានទិន្នន័យ
- រៀបចំផែនការសកម្មភាពចុះអនុវត្ត
- ចុះជួបជាមួយមន្ត្រីលេខាធិការដ្ឋានៈ
  - ការបង្ហាញពីគោលបំណង នឹងវិធីសាស្ត្រ (ចំនួនសំណាកគ្រួសារ អាសយដ្ឋាន របៀបអនុវត្ត)
  - ណែនាំពីការប្រើប្រាស់លើមុខងារតាមដាន និងត្រួតពិនិត្យតាមរយៈកម្មវិធី IDPoor App
  - រៀបចំផែនការរួមដើម្បីចុះអនុវត្តការងារ
- ទទួលរបាយការណ៍លទ្ធផលសម្ភាសន៍សំណាកគ្រួសារពីមន្ត្រីលេខាធិការដ្ឋានតាមរយៈ IDPoor App
- ធ្វើការវិភាគ និងរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យគុណភាពទិន្នន័យ
- ផ្សព្វផ្សាយរបាយការណ៍លទ្ធផលនៃការពិនិត្យគុណភាពទិន្នន័យនេះជូនថ្នាក់ដឹកនាំក្រសួងផែនការ និងអ្នកពាក់ព័ន្ធដទៃទៀត។

# ២.២. មន្ត្រីលេខាធិការដ្ឋាន

- ចូលរួមប្រជុំណែនាំស្ដីពីកិច្ចដំណើរការពិនិត្យគុណភាពទិន្នន័យដែលរៀបចំដោយក្រុមការងារថ្នាក់ជាតិ
- រៀបចំផែនការចុះសម្ភាសន៍សំណាកគ្រួសារដែលផ្ដល់ដោយក្រុមការងារថ្នាក់ជាតិ ឬតាមរយៈកម្មវិធី IDPoor App
- ត្រូវប្រើប្រាស់កម្មវិធី IDPoor App ដើម្បីសម្ភាសន៍សំណាកគ្រួសារចៃដន្យ ដោយមានការគាំទ្រពីមន្ត្រីសម្របសម្រួលបច្ចេកទេស
- ត្រូវបញ្ជូនរបាយការណ៍ស្ដីពីលទ្ធផលនៃការសម្ភាសន៍សំណាកគ្រួសារទាំងអស់ទៅមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រថ្នាក់ជាតិ
- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍លទ្ធផលស្ដីពីការពិនិត្យគុណភាពទិន្នន័យដែលរៀបចំដោយក្រុមការងារថ្នាក់ជាតិ។

# ២.៣. មន្ត្រីសម្របសម្រួលបច្ចេកទេស

- ចូលរួមប្រជុំណែនាំស្តីពីកិច្ចដំណើរការពិនិត្យគុណភាពទិន្នន័យដែលរៀបចំដោយមន្ត្រីការងារថ្នាក់ជាតិ
- ជួយមន្ត្រីលេខាធិការដ្ឋានរៀបចំផែនការចុះសម្ភាសន៍សំណាកគ្រួសារ
- ជួយមន្ត្រីលេខាធិការដ្ឋាន ចុះសម្ភាសន៍សំណាកគ្រួសារដោយប្រើប្រាស់កម្មវិធី IDPoor App
- ចូលរួមប្រជុំផ្សព្វផ្សាយរបាយការណ៍លទ្ធផលស្តីពីការពិនិត្យគុណភាពទិន្នន័យដែលរៀបចំដោយមន្ត្រីការងារថ្នាក់ជាតិ។



ក្រសួងផែនការ

# សូមអរគុណ

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង

idpoor.gov.kh

fb.com/IDPoor Cambodia

https://t.me/idpoorcambodia

youtube.com/IDPoor Cambodia

023 726 814